00894198

លេខ: 56/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 20 / 03 / 2013
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣

ភាសា ៖ អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់បំផុត ប្តូរទៅជាសាធារណៈ:

# សេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទឡើងវិញលើកទីពីរទាក់ទងនឹង សំណើសុំការតែងតាំងសហមេធាវីដែលត្រូវបានតែងតាំង

**ផ្ញើជូន**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**ចម្លងជូន**
**អង្គភាពគាំពារការពារក្តី**
លោក Isaac Endeley

**សហមេធាវីដែលត្រូវបានតែងតាំង**
លោក អាង ឧត្តម
លោក Michael Karnavas

00894199

០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស. លេខ/No: 56/5

1. បានឃើញ មាត្រា ២១ នៃកិច្ចព្រមព្រៀងដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា និងអន្តរជាតិ ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

2. បានឃើញ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

3. បានឃើញ វិធាន ២១ វិធាន ២២ វិធាន ៥៥ វិធាន ៧១ និងវិធាន ៧២ នៃវិធានផ្ទៃក្នុងអ.វ.ត.ក ("វិធានផ្ទៃក្នុង")។

4. បានឃើញ មាត្រា ៦.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី អ.វ.ត.ក ("បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី)។

5. បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងនឹងសំណុំរឿង ០០៣ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ")[១] ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងកាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[២]។

6. បានឃើញ កិច្ចស៊ើបសួរទាក់ទិននឹងបទចោទប្រកាន់អំពីការរំលោភបំពានលើក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣, ៥, ៦, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦។

---

[១] សំណុំរឿង០០៣ ឯកសារD1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[២] សំណុំរឿង០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

7. **បានឃើញ** កំណត់ហេតុនៃករណីខ្វែងយោបល់គ្នាដែលបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Harmon នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។

8. **បានពិចារណាទៅលើ** ការជូនដំណឹងអំពីការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារីនៅសំណុំរឿងដែលបានដាក់ជូនដោយលោកអាង ឧត្តម និងលោកMichael G. KARNAVAS ("សហមេធាវីដែលត្រូវបានតែងតាំង")នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣("សំណើ")។

9. **បានពិចារណាផងដែរទៅលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំកំណត់កាលបរិច្ឆេទជាថ្មី** សម្រាប់ការដាក់សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ ("សំណើសុំកំណត់កាលបរិច្ឆេទជាថ្មី")។

## សង្ខេបសំណើ

10. សហចៅក្រមស៊ើបអង្កេតបានទទួលសំណើមួយពីសហមេធាវីដែលត្រូវបានតែងតាំង ដែលបានស្នើថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ដោយសារមរណភាពរបស់កូនក្ដីរបស់ខ្លួន គឺ អៀង សារី "*បង្កើតជាបច្ច័យមួយធ្វើឱ្យអស់ភាពទាក់ទងទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញាដែលថា ការតែងតាំងសហមេធាវីការពារក្ដីត្រូវបដិសេធដោយឈរលើមូលដ្ឋានថាទំនាស់ផលប្រយោជន៍មិនអាចដោះស្រាយបាន*" ("សំណើសុំបដិសេធរបស់ការិយាល័យសហព្រះរាជអាជ្ញា"[៣]) ហើយសហមេធាវីដែលត្រូវបានតែងតាំងក៏បានស្នើសុំឱ្យ សហចៅក្រមស៊ើបអង្កេត "លើកលែងចោលនូវដីការបស់ខ្លួនដែលហាមឃាត់ការប្រាស្រ័យទាក់ទង"ជាមួយកូនក្ដីរបស់ខ្លួន("ជនសង្ស័យ")នៅក្នុងសំណុំរឿង ០០៣។

11. នៅថ្ងៃដដែលនោះ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំកំណត់កាលបរិច្ឆេទជាថ្មីដោយបានកត់សម្គាល់ថា មរណភាពរបស់អៀង សារី "*បង្កើតបានជាការប្រែប្រួលមួយនៅក្នុងកាលៈទេសៈដែលអាចនឹងមានការទាក់ទងដល់ការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតទៅលើ*

[៣] សំណុំរឿង០០៣ ឯកសារD56/1 ការិយាល័យសហព្រះរាជអាជ្ញា *សំណើសុំរបស់សហព្រះរាជអាជ្ញាដែលថា ការតែងតាំងសហមេធាវីការពារក្ដីត្រូវបដិសេធដោយឈរលើមូលដ្ឋានថាទំនាស់ផលប្រយោជន៍មិនអាចដោះស្រាយបាន*។

*បាតិភ័យដែលធ្វើជាមេធាវីការពារក្តីពីរ...អាចនឹងបណ្តាលឲ្យមានជាទំនាស់ផលប្រយោជន៍ ឬបើពុំដូច្នោះទេ អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរមិនអាចកែប្រែបានទៅលើកិច្ចការរដ្ឋបាលតុលាការ*។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យ សហចៅក្រមស៊ើបអង្កេត ចេញការកំណត់កាលបរិច្ឆេទថ្មីដើម្បីអនុញ្ញាតឲ្យ៖ (១)សហព្រះរាជអាជ្ញាមានរយៈពេលសមស្របក្នុងការដាក់ជូននូវសំណើមួយដែលបានពិនិត្យជាថ្មី (២)សហមេធាវីការពារក្តីដែលបានចាត់តាំងអាចដាក់ចម្លើយតប និង(៣)សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតប[៤]។

## ការពិភាក្សា

12. មរណភាពរបស់អៀង សារី បានកើតឡើងមុនពេលដែលចម្លើយតបមួយត្រូវបានទទួលពីសហព្រះរាជអាជ្ញា តាមកាលបរិច្ឆេទលើកមុនដែលបានកំណត់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងបញ្ហានេះ[៥]។ លើសពីនេះទៀត ភាគីពាក់ព័ន្ធទាំងពីរ បញ្ជាក់ថាហេតុការណ៍នេះអាចមានឥទ្ធិពលធ្ងន់ធ្ងរទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបដិសេធរបស់ការិយាល័យសហព្រះរាជអាជ្ញា។

13. អាស្រ័យហេតុនេះ នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី ហាក់ដូចជាមានការប្រុងប្រយ័ត្នដែលត្រូវពន្យារពេលធ្វើសេចក្តីសម្រេចលើការបញ្ជាក់ការតែងតាំងមេធាវីដែលត្រូវបានតែងតាំងបណ្តោះអាសន្នដោយអង្គភាពគាំពារការពារក្តី រហូតទាល់តែ មេធាវីដែលត្រូវបានតែងតាំង និងសហព្រះរាជអាជ្ញា មានឱកាសដាក់សេចក្តីសន្និដ្ឋាន និងសារណាបន្ថែមទៀតស្តីពីផលប៉ះពាល់នៃការប្រែប្រួលកាលៈទេសៈអង្គហេតុទាំងនេះទៅលើបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុងសំណើសុំបដិសេធរបស់ការិយាល័យសហព្រះរាជអាជ្ញា។

---

[៤] សំណើសុំកំណត់កាលបរិច្ឆេទជាថ្មី កថាខណ្ឌ ៣។

[៥] សំណុំរឿង00៣ ឯកសារD56/3 *សេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទឡើងវិញទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីដែលត្រូវបានតែងតាំង* ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងសំណុំរឿង00៣ ឯកសារD56/4 *ដីកាកំណត់កាលបរិច្ឆេទឡើងវិញទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីដែលត្រូវបានតែងតាំង*ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣។

**អាស្រ័យហេតុនេះ ខ្ញុំ MARK B. HARMON សម្រេច**

14. **បដិសេធ** សំណើរបស់សហមេធាវីដែលត្រូវបានតែងតាំង ហើយ**បញ្ជាក់**អំពីដីកាលើកមុនដែលបង្គាប់ឱ្យលោក អាង ឧត្តម លោក Karnavas ព្រមទាំងសហការីរបស់ពួកគាត់ ផ្អាកការប្រាស្រ័យទាក់ទងជាមួយនឹងជនសង្ស័យ រហូតទាល់តែសហចៅក្រមស៊ើបអង្កេតចេញសេចក្តីសម្រេចទៅលើការបញ្ជាក់អំពីការតែងតាំងរបស់ពួកគាត់ ។

15. **ទទួលយក** សំណើសុំកំណត់កាលបរិច្ឆេទជាថ្មី ដូច្នេះហើយ

- **ពន្យារពេល** ធ្វើការពិចារណាទៅលើដីកាសម្រេចស្តីពីការទទួលស្គាល់សហមេធាវីដែលត្រូវបានតែងតាំងតំណាងជនសង្ស័យ រហូតទាល់តែ ពួកគាត់ និងសហព្រះរាជអាជ្ញាមានឱកាសដាក់សេចក្តីសន្និដ្ឋាន និងសារណាបន្ថែមទៀតស្តីពីលទ្ធភាពមានទំនាស់ផលប្រយោជន៍ចាប់តាំងពីមរណភាពរបស់ អៀង សារី ។

- **រំឭកថា** សហមេធាវីដែលត្រូវបានតែងតាំង គឺស្ថិតនៅក្រោមកាតព្វកិច្ចជាបន្តបន្ទាប់ដើម្បីធានាឱ្យមានការរក្សាការសម្ងាត់នូវសម្ភារៈឯកសារទាំងអស់ដែលខ្លួនបានទទួលទាក់ទងនឹងបញ្ហានេះ ហើយត្រូវប្រគល់ឯកសារទាំងនោះជូនក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតវិញនៅពេលដែលមានសេចក្តីសម្រេចចុងក្រោយលើសំណើសុំតែងតាំង។

- **អញ្ជើញ** សហព្រះរាជអាជ្ញា ដាក់សេចក្តីសន្និដ្ឋានស្តីពីលទ្ធភាពមានជំនាស់ផលប្រយោជន៍ចំពោះសហមេធាវីដែលត្រូវបានតែងតាំង ជាមេធាវីតំណាងជនសង្ស័យចាប់តាំងពីមរណភាពរបស់ អៀង សារី ក្នុងរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការនៅពេលចេញសេចក្តីសម្រេចនេះ។

- **អញ្ជើញ** សហមេធាវីដែលត្រូវបានតែងតាំង ឱ្យដាក់សារណាឆ្លើយតបក្នុងរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការនៅពេលដែលសហព្រះរាជអាជ្ញា បានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួន ។

- **អញ្ជើញ** សហព្រះរាជអាជ្ញា ឱ្យឆ្លើយតបទៅនឹងសារណារបស់សហមេធាវីដែលត្រូវបានតែងតាំង ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការនៅពេលដែលសហមេធាវីដែលត្រូវបាន

00894203



តែងតាំង បានដាក់សារណារបស់ពួកគាត់ ។

- **សម្រេច** ដាក់ឯកសារបន្ថែមដែលទទួលបានរហូតមកដល់សព្វថ្ងៃនេះ ចូលទៅក្នុងសំណុំរឿងក្រោមឯកសារលេខ D56/4/2(សំណើរបស់សហមេធាវីដែលត្រូវបានតែងតាំង និងឯកសារភ្ជាប់ជាមួយ) និង D56/4/3(សំណើសុំកំណត់កាលបរិច្ឆេទជាថ្មីរបស់ការិយាល័យសហព្រះរាជអាជ្ញា ។

- **ប្រកាសថា** រហូតដល់ពេលដែលបញ្ហានេះត្រូវបានសម្រេចជាចុងក្រោយ រាល់ការដាក់ឯកសារទាំងអស់ត្រូវចាត់ទុកថាជាឯកសារ**សម្ងាត់បំផុត**។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣

**Mark Brian Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**